**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រះសីហនុ**
សំណុំរឿងរដ្ឋប្បវេណីលេខ២៧៨
ចុះថ្ងៃទី៧ ខែ ធ្នូ ឆ្នាំ២០២០
**សាលក្រមលេខ ៤០ /០១ (ឆ)**
ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ២០២១

**សាលក្រម**
**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តព្រះសីហនុ**

*បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅ*
*ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១*

**ចៅក្រមជំនុំជម្រះ**

*លោក [redacted] ជាសាលាដំបូងខេត្តព្រះសីហនុ*

**ក្រឡាបញ្ជី**

*លោក [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តព្រះសីហនុ*

-**ដើមចោទ**ឈ្មោះ [redacted] **សាក់** ភេទស្រី អាយុ៣១ឆ្នាំ ជាតិខ្មែរ មានទី[redacted]។ ។(អវត្តមាន)

**មានមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ៖**

១.លោកមេធាវី [redacted] អត្តលេខ៖ ៨០៨ មាន[redacted]។ (វត្តមាន)

២.លោកមេធាវី [redacted] អត្តលេខ [redacted] មានការិយាល័យ៖[redacted]។ (វត្តមាន)

៣.លោកមេធាវី [redacted] អត្តលេខ [redacted] មានការិយាល័យ[redacted]។ (អវត្តមាន)

-**សហចុងចម្លើយ**

១.ឈ្មោះ [redacted] Tianxing ជនជាតិចិន [redacted] កាន់លិខិតឆ្លងដែន E81636330 ចុះថ្ងៃទី២៩ខែកក្កដាឆ្នាំ២០១១ មានទីលំនៅ[redacted]។ (អវត្តមាន)

២.ឈ្មោះ [redacted] Mengchun ជនជាតិចិន [redacted] កាន់លិខិតឆ្លងដែន [redacted] ចុះថ្ងៃទី១៩ខែកក្កដាឆ្នាំ២០១១ មានទីលំនៅ[redacted] ។(អវត្តមាន)

**មានមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] Tianxing ៖**

១.លោកមេធាវី **ម៉ុច ពៅ** អត្តលេខ ១៤០៣ មានការិយាល័យ[redacted]។(អវត្តមាន)

២.លោកមេធាវ[redacted]អត្តលេខ ២៨៥ មានការិយាល័យនៅអគា[redacted] ។(អវត្តមាន)

៣.លោកមេធាវ[redacted] អត្តលេខ១៥៤៩ មានការិយាល័យនៅអគារ[redacted] ។(អវត្តមាន)

## អង្គហេតុ និង ចំណុចវិវាទ

### ក- ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ

១-បង្គាប់ឱ្យសហចុងចម្លើយសងប្រាក់មកដើមចោទឈ្មោះ [redacted] សាក់ ចំនួន ១.០០០.០០០ (មួយលាន)ដុល្លារអាមេរិក ។

២-ឱ្យបង្គាប់ឱ្យសហចុងចម្លើយសងប្រាក់យឺតយ៉ាវមកឈ្មោះ [redacted] សាក់ ចំនួន៣០៨.០០០ (សាមសិបម៉ឺនប្រាំបីពាន់)ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០២០ ដល់ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០២០ ( ប្រាក់ដែលសហចុងចម្លើយមិនបានបង់ចំនួន១១ខែ) ។

៣-បង្គាប់ឱ្យសហចុងចម្លើយសងការប្រាក់មកឈ្មោះ [redacted] សាក់ គិតចាប់ពីថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០២០ រហូតដល់ថ្ងៃធ្វើការទូទាត់ចប់សព្វគ្រប់ ។ (ការប្រាក់ដែលគិតចាប់ពីថ្ងៃដាក់ពាក្យបណ្ដឹងរហូតអនុវត្តចប់) ។

៤-បង្គាប់ឱ្យសហចុងចម្លើយសងប្រាក់ពិន័យមកឈ្មោះ [redacted] សាក់ ចំនួន ១០៨.០០០ (មួយសែនប្រាំបីពាន់) ដុល្លារអាមេរិក ។

៥-បង្គាប់ឱ្យសហចុងចម្លើយសងសំណងនូវការខូចខាត និងសំណងជំងឺចិត្តមកឈ្មោះ [redacted] សាក់ ចំនួន២០០.០០០( ម្ភៃម៉ឺន)ដុល្លារអាមេរិក ។

៦-សុំប្រកាសអនុវត្តសាលក្រមនេះ មានអានុភាពអនុវត្តបណ្ដោះអាសន្ន ដើម្បីជៀសវាងការអូសបន្លាយពេលវេលាអនុវត្ត និងខាតប្រយោជន៍របស់ម្ចាស់បំណុលកាន់តែធ្ងន់ធ្ងរថែមទៀត។

៧-បង្គាប់ឱ្យសហចុងចម្លើយទទួលរ៉ាប់រងនូវប្រាក់ប្រដាប់ក្ដី និង ពន្ធផ្សេងៗ ក្នុងដំណើរការនីតិវិធីរបស់តុលាការ ។



Scanned with CamScanner

**ខ. អំពីដំណើររឿងក្តី និងចំណុចវិវាទ**

**ខ. ១ ការសង្ខេបអំពីរឿងក្តី**

កាលពីថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ សហចុងចម្លើយឈ្មោះ [redacted] TIANXING និងអ្នកជានាឈ្មោះ [redacted] CHUN បានធ្វើកិច្ចសន្យាប្រគល់ និងទទួលប្រាក់កម្ចីចំនួន ១.០០០.០០០(មួយលាន) ដុល្លាអាមេរិក ពីឈ្មោះ [redacted] **សាគ់** (ដែលជាតំណាងក្រុមហ៊ុន[redacted]) និងបានធ្វើកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ រវាងតំណាងក្រុមហ៊ុន[redacted] តំណាងដោយឈ្មោះ [redacted] **សាគ់** (អ្នកឱ្យខ្ចី) និងអ្នកខ្ចីឈ្មោះ [redacted] TIANXING និងអ្នកជានាឈ្មោះ [redacted] CHUN ដោយនៅក្នុងកិច្ចសន្យាខ្ចីបរិភោគនេះ មានចែងក្នុងប្រការ២ គឺបានកម្ចីប្រាក់ចំនួន ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក និងប្រការ៣ បានព្រមព្រៀងអាត្រាការប្រាក់ក្នុងមួយខែ ២.៨% ហើយនៅក្នុងប្រការ៤ ចំណុច១. ប្រាក់កម្ចី និងរយៈពេលសងគិតចាប់ពីថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៩ ។ ចំណុច២. ត្រូវទូទាត់សងប្រាក់ នៅរៀងរាល់ថ្ងៃទី៥នៃខែនីមួយៗ នៅចំណុចទី៣ បានចែងថា ប្រសិនបើដល់កាលកំណត់សងប្រាក់កម្ចីសងអ្នកខ្ចី មិនទូទាត់សងប្រាក់ដើម និងការប្រាក់មានការយឺតយ៉ាវបង់ប្រាក់ គឺក្នុងអាត្រាការប្រាក់១០% ។ ការយឺតយ៉ាវហួសពី១០ថ្ងៃ ប្រសិនបើអ្នកខ្ចី មិនទូទាត់ប្រាក់ដើម និងការប្រាក់គ្រប់ចំនួន អាចកាត់យកទ្រព្យបញ្ចាំដែលអ្នកខ្ចីបានដាក់ (ដីដែលមានប័ណ្ណលេខ១៨០១០៣០១-០៣៦៤ និង ប័ណ្ណលេខ ១៨០១០៣០១-០៣៦៥) ។

ចាប់ពីពេលចុះកិច្ចសន្យាប្រគល់ទទួលប្រាក់ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៩ រហូតមកថ្ងៃដើមចោទ ដាក់ពាក្យបណ្តឹងទាមទារ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០២០ សហចុងចម្លើយ ពុំដែលបានបង់អត្រាការប្រាក់ និងប្រាក់ដើមមកឱ្យដើមចោទរហូតមកដល់បច្ចុប្បន្ន ។

**ខ. ២ អង្គហេតុដែលគ្មានវិវាទ**

ខ.២.១ ដើមចោទ និងសហចុងចម្លើយ បានឯកភាពគ្នា ៖

-ធ្វើកិច្ចសន្យាប្រគល់ទទួលប្រាក់បរិភោគចំនួន១.០០០.០០០ (មួយលាន) ដុល្លាអាមេរិក ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ។

-កិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ គូភាគីបានកំណត់រយៈពេលសងគឺពីថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៩ ក្នុងអាត្រាការប្រាក់ ២.៨%ក្នុងមួយខែ ។

-កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០២០ គូភាគីបានព្រមព្រៀងគ្នា ដោយអ្នកឱ្យខ្ចី យល់ព្រមផ្តល់ឱ្យអ្នកខ្ចី នូវសាច់ប្រាក់ចំនួន១.០០០.០០០(មួយលាន)ដុល្លារ

អាមេរិកដែលប្រាក់កម្ចីនេះ នឹងត្រូវបញ្ចេញឱ្យអ្នកខ្ចីស្របតាមប្រការ១. រហូតដល់ប្រការទី៧នៃកិច្ចសន្យា ។

-កិច្ចសន្យាជានា ចុះថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០២០ គូភាគី បានព្រមព្រៀងគ្នានៅក្នុងប្រការទី១ រហូតដល់ប្រការទី៩ នៃកិច្ចសន្យា ។

**ខ. ៣ ចំណុចវិវាទ**

ខ.៣.១.តើដើមចោទ បានប្រគល់ប្រាក់ចំនួន ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិកឱ្យទៅភាគីសហចុងចម្លើយដែរឬទេ ?

**ខ. ៤ ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទ**

ខ.៤.១ លោកមេធាវី [redacted] បានថ្លែងការណ៍នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់៖

១.ការទាមទារឲ្យសហចុងចម្លើយសងប្រាក់កម្ចីដើមចោទចំនួន ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក ដោយផ្អែកទៅលើកិច្ចសន្យាខ្ចីបរិភោគដែលបានបង្កើតឡើង រវាងដើមបណ្តឹង និង សហចុងចម្លើយ ចុះថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០២០ តាមរយៈកិច្ចសន្យានេះ សហចុងចម្លើយ បានចុះ កិច្ចសន្យាខ្ចីបរិភោគចំនួន ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក ក្រោយពីបានចុះកិច្ចសន្យារួចមក សហចុងចម្លើយ ពុំបានសងប្រាក់កម្ចីមកឲ្យដើមចោទនោះទេ ។

២.ការទាមទារឲ្យសហចុងចម្លើយសងការប្រាក់យឺតយ៉ាវ ចំនួន ៣០៨.០០០ (បីសែនប្រាំបីពាន់) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០២០ ដល់ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០២០ (ការប្រាក់ដែលសហចុងចម្លើយមិនបានបង់ចំនួន១១ខែ) ។ ដោយយោងលើកិច្ចសន្យាខ្ចីបរិភោគ ត្រង់ចំណុច១.៣ បានចែងអំពីអត្រាការប្រាក់ដែលត្រូវបង់ ដូច្នេះ សហចុងចម្លើយ ត្រូវមានកាតព្វកិច្ចសងការប្រាក់តាមកិច្ចសន្យាខាងលើ ។

៣.បង្គាប់ឲ្យសហចុងចម្លើយសងការប្រាក់មកឈ្មោះ[redacted] **សាក់** គិតចាប់ពីថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០២០ រហូតដល់ថ្ងៃធ្វើការទូទាត់ចប់សព្វគ្រប់ (ការប្រាក់ដែលគិតចាប់ពីថ្ងៃដាក់ពាក្យបណ្តឹងរហូតអនុវត្តចប់) ។

ដោយហេតុថាកិច្ចសន្យាខ្ចីបរិភោគដែលបានបង្កើតឡើង រវាងដើមបណ្តឹង និង សហចុងចម្លើយ ពុំទាន់បានអនុវត្តចប់ តាមការសន្យារបស់សហចុងចម្លើយ និង កិច្ចសន្យា នៅមានសុពលភាព នៅឡើយ ។

៤.បង្គាប់ឲ្យសហចុងចម្លើយសងប្រាក់ពិន័យមកឈ្មោះ [redacted] **សាក់** ចំនួន ១០៨.០០០ (មួយសែនសូន្យម៉ឺនប្រាំបីពាន់) ដុល្លារអាមេរិក ។

ដោយហេតុថាសហចុងចម្លើយយល់ព្រមទទួល ការផាកពិន័យចំនួន០១(មួយ)ភាគរយក្នុង០១ (មួយ)ថ្ងៃនៃការប្រាក់ដែលមិនបានសងទៅឱ្យដើមបណ្តឹង(ប្រាក់ពិន័យត្រង់ចំនុចនេះមានន័យថា សហចុងចម្លើយពុំបានទៅបង់ប្រាក់ដើមនិងការប្រាក់ តាមកាលកំណត់នៃថ្ងៃត្រូវបង់) ។

៥.ការទាមទារឱ្យសហចុងចម្លើយ សងសំណងនូវការខូចខាត និងសំណងជំងឺចិត្តចំនួន ២០០.០០០ (ពីរសែន) ដុល្លារអាមេរិក ដោយហេតុថាសហចុងចម្លើយ មិនបានគោរព និង អនុវត្ត នូវកាតព្វកិច្ច ក្នុងការសងបំណុលទៅដើមបណ្តឹងដែលធ្វើមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់ការវិនិយោគទុនរបស់ដើមបណ្តឹងនាពេលបច្ចុប្បន្ននេះ ។

៦.សុំឱ្យសាលក្រមនេះ មានអានុភាពអនុវត្តបណ្តោះអាសន្នទាំងមូល ដោយហេតុថាទោះបីជា រឿងក្តីដល់តុលាការជាន់ខ្ពស់ ក៏នៅតែសម្រេចឲ្យសហចុងចម្លើយសងប្រាក់មកដើមចោទដដែល ដើម្បីជៀសវាងការអូសបន្លាយពេលវេលាអនុវត្តកាតព្វកិច្ច និងខាតប្រយោជន៍ របស់ដើមបណ្តឹងកាន់តែធ្ងន់ធ្ងរថែមទៀត ។

៧.បង្គាប់ឱ្យសហចុងចម្លើយ ត្រូវទទួលរ៉ាប់រងនូវប្រាក់ប្រដាប់ក្តី និងពន្ធផ្សេងៗក្នុងដំណើរការនីតិវិធីរបស់តុលាការ ដោយហេតុថាជាកំហុសរបស់សហចុងចម្លើយដែលមិនគោរពកាតព្វកិច្ចបង់ប្រាក់តាមកិច្ចសន្យាខ្ចីប្រាក់ជាមួយដើមបណ្តឹង ។ លោកមេធាវី [redacted] និងលោក [redacted] បានថ្លែងការណ៍នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា យោងតាមការស្នើសុំខ្ចីប្រាក់ចំនួន ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក របស់សហចុងចម្លើយឈ្មោះ [redacted] Tianxing កូនក្តីខ្លួនបានធ្វើកិច្ចសន្យាខ្ចីបរិភោគដូចខាងក្រោម ៖

១) កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ (ភ័ស្តុតាង II)

២) កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០២០ (ភ័ស្តុតាង III) និងបានចុះកិច្ចសន្យាធានាជាមួយនឹងសហចុងចម្លើយឈ្មោះ [redacted] Mengchun ដូចខាងក្រោម៖

៣) កិច្ចសន្យាធានា ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០២០ (ភ័ស្តុតាង IV)

ប្រាក់ចំនួន ១.០០០.០០០ (មួយលាន)ដុល្លារអាមេរិក មិនត្រូវបានសហចុងចម្លើយឈ្មោះ [redacted]Tianxing និង ឈ្មោះ [redacted] Mengchun បង្វិលសងមកកូនក្តីខ្លួន រហូតមកដល់បច្ចុប្បន្ននេះ ។ ជាការបំពានកាតព្វកិច្ចធ្ងន់ធ្ងរជាងនេះទៀត គឺសហចុងចម្លើយ មិនព្រមបង់ការប្រាក់ និងប្រាក់យឺតយ៉ាវ រួមទាំងប្រាក់ពិន័យជូនកូនក្តីខ្លួនថែមទៀត ។

ដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០២០ ប្រាក់កម្ចីចំនួន ១.០០០.០០០(មួយលាន)ដុល្លារអាមេរិក កូនបំណុលឈ្មោះ [redacted] Tianxing និងអ្នកធានា ឈ្មោះ



Scanned with CamScanner

[redacted] Mengchun ពុំបានអនុវត្តកាតព្វកិច្ច ដូចមានចែងក្នុងចំណុច១.៣ នៃប្រការ១ (គូភាគីព្រមព្រៀងថាប្រាក់កម្ចីមានភ្ជាប់ការប្រាក់ចំនួន២,៨% (**ពីរក្បៀសប្រាំបី ភាគរយ**) ក្នុង១ខែ (ដែលតទៅនេះហៅថា "ការប្រាក់កម្ចី") គិតចាប់ពីថ្ងៃចុះកិច្ចសន្យា ដោយការប្រាក់ ត្រូវបង់ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០២០) និងចំណុច២.២នៃប្រការ២ (រយៈពេលនៃកម្ចីគឺ **១** (មួយ) ខែ ដោយគិតចាប់ពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០២០ ដល់ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០) ព្រមទាំង ចំណុច២.៣ (លើកលែងមានការព្រមព្រៀងផ្សេងពីនេះ ដោយគូភាគី អ្នកខ្ចីត្រូវសងប្រាក់កម្ចីនៅ ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០២០) រហូតមកដល់ពេលនេះដែលការបំពានកាតព្វកិច្ចនេះ បានធ្វើឲ្យខាតប្រយោជន៍យ៉ាងធ្ងន់ធ្ងរ ដល់កូនក្តីយើងខ្ញុំ យោងតាមមាត្រា ៥៧៨ មាត្រា ៥៨១ មាត្រា ៩០០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៥៧៨ ក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុតអ្នកខ្ចីមានករណីកិច្ចសងទៅឱ្យអ្នកឱ្យខ្ចីវិញនូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួនស្មើគ្នានឹងវត្ថុដែលបាន ទទួលអ្នកឱ្យខ្ចីនោះ ។

មាត្រា ៥៨១ ប្រសិនបើស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចី ធ្លាក់ចុះយ៉ាងខ្លាំង ដែលនឹងធ្វើឱ្យមានឧបសគ្គដល់ការអនុវត្តកាតព្វកិច្ចសង អ្នកឱ្យខ្ចីអាចរំលាយកិច្ចសន្យាខ្ចីបរិភោគបាន ។

មាត្រា ៩០០ ដោយសារបុគ្គលដែលមានបំណងធ្វើជាអ្នកធានា បានសន្យាជាមួយនឹងម្ចាស់បំណុលថា ខ្លួននឹងអនុវត្តកាតព្វកិច្ចមួយផ្នែក ឬទាំងមូលជាមួយនឹងកូនបំណុល ដែលមានកាតព្វកិច្ចចម្បង នៅក្នុងករណីដែលកូនបំណុលមានកាតព្វកិច្ចចម្បង នោះ ពុំអនុវត្តកាតព្វកិច្ចរបស់ខ្លួន ។

ឈ្មោះសហចុងចម្លើយ៖ ឈ្មោះ [redacted] Tianxing ភេទប្រុស ជនជាតិចិន កាន់លិខិតឆ្លងដែនលេខ៖ [redacted] ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ [redacted] ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ៖ **២៧៨** ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ។

### ខ. ៥ ការអះអាងរបស់មេធាវីតំណាងឱ្យសហចុងចម្លើយ

លោកមេធាវី [redacted] តំណាងឱ្យសហចុងចម្លើយឈ្មោះ [redacted] Tianxing បានថ្លែងការណ៍នៅដំណាក់កាលធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា ចំពោះការប្តឹងទាមទាររបស់ដើមចោទ ទៅលើកូនក្តីខ្លួននោះ ខ្លួនទទួលស្គាល់ថា ដើមចោទ និង ចុងចម្លើយពិតជាបានធ្វើកិច្ចសន្យាពិតមែន ប៉ុន្តែការអនុវត្តធ្វើកិច្ចសន្យានេះ ខ្លួនសុំធ្វើការបដិសេធចោលទាំងអស់ ពីព្រោះ

កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០២០ រវាងអ្នកខ្ចី និងអ្នកឱ្យខ្ចី មិនបានអនុវត្តទេ គឺមិនមានការប្រគល់ទទួលប្រាក់កម្ចីទេ ។

**គ. ភស្តុតាងដែលគូភាគីបានដាក់ជូនតុលាការពិនិត្យ**

**គ. ១.ភស្តុតាងដែលដើមចោទបានដាក់ជូនតុលាការ**

គ.១.១. កិច្ចសន្យាប្រគល់និងទទួលប្រាក់ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ។

គ.១.២.កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ។

គ.១.៣.កិច្ចសន្យាបរិភោគ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០២០ ។

គ.១.៤.កិច្ចសន្យាធានា ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០២០ ។

គ.១.៥.បង្កាន់ដៃទទួលប្រាក់ ចុះថ្ងៃទី៥ខែវិច្ឆិកាឆ្នាំ២០១៩ ។

គ.១.៦.សក្ខីបត្របញ្ចេញសាច់ប្រាក់ ចុះថ្ងៃទី៥ខែវិច្ឆិកាឆ្នាំ២០១៩ ។

គ.១.៧.បង្កាន់ដៃទទួលប្រាក់ ចុះថ្ងៃទី៤ខែវិច្ឆិកាឆ្នាំ២០១៩ ។

គ.១.៨.សក្ខីបត្របញ្ចេញសាច់ប្រាក់ ចុះថ្ងៃទី៤ខែវិច្ឆិកាឆ្នាំ២០១៩ ។

គ.១.៩.បង្កាន់ដៃទទួលប្រាក់ ចុះថ្ងៃទី៥ខែតុលាឆ្នាំ២០១៩ ។

គ.១.១០.សក្ខីបត្របញ្ចេញសាច់ប្រាក់ ចុះថ្ងៃទី៦ខែវិច្ឆិកាឆ្នាំ២០១៩ ។

**គ. ២.ភស្តុតាងដែលចុងចម្លើយបានដាក់ជូនតុលការ**

គ.១.២.១.កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០២០ ។

គ.១.២.២.វិក័យបត្រអេឡិកត្រូនិក្ស ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២០ ។

គ.១.២.៣.វិក័យបត្រទូរទាត់ចំណាយ ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៩ ។

គ.១.២.៤.វិក័យបត្រទូរទាត់ចំណាយ ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២០ ។

## សំអាងហេតុ

**ក.ស្ដីពីការទាមទារប្រាក់ដើមចំនួន១.០០០.០០០ដុល្លារអាមេរិក**

ក.១. នាពេលទាញហេតុផលដោយផ្ទាល់មាត់ មេធាវីតំណាងដោយអាណត្តិដើមចោទបានថ្លែងការណ៍ថា នៅតែប្ដឹងរក្សាការទាមទារ និងមូលហេតុនៃការទាមទារតាមខ្លឹមសារដែលមាននៅក្នុងពាក្យបណ្ដឹង ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០២០ ។ ផ្អែកលើពាក្យបណ្ដឹងនេះ ឃើញថា មូលហេតុនៃការទាមទារ ដោយសារកាលពីថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ដើមចោទ និងសហចុងចម្លើយ បានបង្កើតកិច្ចសន្យាខ្ចីបរិភោគ និង កិច្ចសន្យាប្រគល់ និងទទួលប្រាក់ ចំនួន

១.០០០.០០០ (មួយលាន) ដុល្លាអាមេរិក មានអាត្រាការប្រាក់ចំនួន ២.៨% ក្នុងមួយខែ ជារៀងរាល់ខែ ។ តែសហចុងចម្លើយ ពុំបានបង់ការប្រាក់ និងសងប្រាក់ដើមទៅឱ្យដើមចោទទេ ចាប់តាំងពីថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៩ ។

ក.២.ផ្អែកតាមភស្តុតាងកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ គូរភាគីបានព្រមព្រៀងគ្នានៅក្នុងកិច្ចសន្យានេះ ត្រង់ចំណុចប្រការ១ រហូតដល់ប្រការទី៦នៃកិច្ចសន្យា ឃើញថា សហចុងចម្លើយ ពិតជាបានខ្ចីប្រាក់ចំនួន ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក មានអាត្រាការប្រាក់ចំនួន ២.៨% ពីក្រុមហ៊ុន គីម គីម ដែលមានឈ្មោះ [redacted] សាក់ តំណាងឱ្យក្រុមហ៊ុន ប្រាកដមែន ។

ក.៣.ផ្អែកតាមភស្តុតាងកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០២០ ឃើញថា ភាគីអ្នកខ្ចី បានខ្ចីពីអ្នកឱ្យខ្ចីនូវប្រាក់កម្ចី ក្នុងទឹកប្រាក់ដូចមានចែងក្នុងប្រការ១.១នៃកិច្ចសន្យានេះ ក្នុងគោលបំណងប្រត្តិបត្តិការគម្រោងកាស៊ីណូសណ្ឋាគារទុនហ័ង នៅលើដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១៨០១០៣០១-០៣៦២និងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១៨០១០៣០១-០៣៦៥ ដែលមានទីតាំងស្ថិតនៅភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។ ហើយគូភាគីបានព្រមព្រៀង នៅក្នុងប្រការ១ រហូតដល់ប្រការ៧ នៃកិច្ចសន្យាខ្ចីបរិភោគនេះ ។

ក.៤.ផ្អែកតាមភស្តុតាងកិច្ចសន្យាធានា ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២០ ឃើញថា អ្នកដាក់បញ្ចាំបានខ្ចីប្រាក់ពីអ្នកទទួលបញ្ចាំនូវប្រាក់កម្ចីដូចមាននៅក្នុងកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០២០ រវាងអ្នកដាក់បញ្ចាំ និងអ្នកទទួលបញ្ចាំ (ហៅថាអ្នកខ្ចីប្រាក់បរិភោគ) ។ អ្នកដាក់បញ្ចាំកាន់កាប់ភាគហ៊ុន១០០% ដោយហេតុថា អ្នកដាក់បញ្ចាំ មានបំណងដាក់បញ្ចាំ ដើម្បីធានាការសងប្រាក់កម្ចី តាមរយៈការបញ្ចាំភាគហ៊ុនក្រុមហ៊ុននិងផលប្រយោជន៍ផ្សេងៗទៀត ដូចកំណត់ក្នុងប្រការ២ (ហៅថាទ្រព្យធានា) ឱ្យអ្នកទទួលបញ្ចាំ ។ នៅក្នុងកិច្ចសន្យាធានានេះ គូភាគី បានព្រមព្រៀងគ្នា តាំងពីប្រការទី១ រហូតដល់ប្រការទី៥ នៃកិច្ចសន្យា ។

ក.៥.ផ្អែកតាមភស្តុតាងសក្ខីបត្របញ្ចេញសាច់ប្រាក់ និងបង្កាន់ដៃទទួលប្រាក់ ឃើញថា សហចុងចម្លើយពិតជាបានទទួលទឹកប្រាក់ចំនួន១.០០០.០០០(មួយលាន)ដុល្លារអាមេរិក ពីឈ្មោះ [redacted] សាក់ តំណាងឱ្យក្រុមហ៊ុន [redacted] ប្រាកដមែន ។

**ខ.ស្តីពីការប្រាក់ចំនួន១,៨%ក្នុង១ឆ្នាំ( ដប់ប្រាំភាគរយ )លើប្រាក់ដើម១.០០០.០០០ ( មួយលាន )ដុល្លារអាមេរិក**

ខ.១ផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ត្រង់ប្រការ២. ប្រការ៣. បានបង្ហាញថា ការប្រាក់ដែលបានកំណត់ក្នុងកិច្ចសន្យាខ្ចីបរិភោគ គឺមានចំនួន ២,៨% (ពីរក្បៀសប្រាំបីភាគរយ)ក្នុងមួយខែ ។

យោងតាមក្រមរដ្ឋប្បវេណី ភាគីនៃកិច្ចសន្យាខ្ចីបរិភោគ អាចព្រមព្រៀងគ្នាកំណត់ពីអត្រាការប្រាក់បាន តែអត្រាការប្រាក់នោះ មិនត្រូវលើសពីអត្រាការប្រាក់ដែលច្បាប់កំណត់ឡើយ ។ បើពិនិត្យក្នុងប្រការ១ នៃប្រកាសលេខ ១២៨ កយ.ប្រក/១១ របស់ក្រសួងយុត្តិធម៌ បានកំណត់ថា អត្រាការប្រាក់នេះ ត្រូវកំណត់មិនឱ្យលើសពី ១៨% (ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ ដូច្នេះការកំណត់អត្រាការប្រាក់របស់ភាគីខាងលើ ជាប្រាក់កំណត់ដែលមានលក្ខណៈមិនត្រឹមត្រូវស្រប តាមច្បាប់ទេ ។

ខ.២.យោងសំអាងហេតុត្រង់ចំណុច ក ខាងលើ ឃើញថា ប្រាក់ដើមដែលសហចុងចម្លើយជំពាក់ មានចំនួន**១.០០០.០០០**(មួយ**លាន**)**ដុល្លារអាមេរិក** រីឯការប្រាក់មិនបានបង់ គឺ នៅថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៩។ ដូចនេះ ដើមចោទមានអត្ថិភាពនៃសិទ្ធិទាមទារឱ្យសហចុងចម្លើយបង់ការប្រាក់ចំនួន ១៨% (ដប់ប្រាំបីភាគរយ ) ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន **១.០០០.០០០**(មួយ**លាន**)**ដុល្លារអាមេរិក** គិតថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៩។

ខ.៣. ចំពោះការទាមទារឱ្យបង់ការប្រាក់រហូតទូរទាត់ចប់ឱ្យដើមចោទ ជាការទាមទារដែលមិនត្រឹមត្រូវតាមច្បាប់ទេ ដោយហេតុថា ការខ្ចីប្រាក់នេះ មានកំណត់អំពីការប្រាក់ផង និងប្រាក់ពិន័យផង ។ម្យ៉ាងទៀតក្នុងកិច្ចសន្យានេះ មានកាលកំណត់សងរយៈពេល១ខែ ក៏មានន័យថា ការទាមទារឱ្យបង់ការប្រាក់ ត្រូវទាមទារឱ្យបង់ ដោយគិតចាប់ពេលមិនបានបង់ រហូតដល់កាលកំណត់សងបានផុត ។ ដូច្នេះតុលាការ បង្គាប់ឱ្យសហចុងចម្លើយរួមគ្នា សងការប្រាក់ចំនួន ១៨% (ដប់ប្រាំបីភាគរយ ) ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន**១.០០០.០០០**(មួយ**លាន**)**ដុល្លារអាមេរិក** គិតចាប់ពីថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៩។

**គ.ស្តីពីការទាមទារសំណងការខាតដោយសារយឺតយ៉ាវ គិតចាប់ពីថ្ងៃទី៥ ខែ វិច្ឆិកា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងរួច**

គ.១.នៅក្នុងកិច្ចន្យាខ្ចីបរិភោគ ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ក្នុងប្រការ៤ ចំណុចទី៣ បង្ហាញថា ពិតជាមានកំណត់ថា ប្រសិនដល់កាលកំណត់សង អ្នកខ្ចីមិនអាចទូទាត់សងប្រាក់ដើម និងការប្រាក់ការយឺតយ៉ាវ គឺក្នុងអត្រា១០% ។ ការប្រាក់ពិន័យដែលកំណត់ក្នុងកិច្ចសន្យានេះ ជាការប្រាក់យឺតយ៉ាវ ត្រូវបានក្រមរដ្ឋប្បវេណីអនុញ្ញាតឱ្យភាគីកំណត់ពីការប្រាក់យឺតយ៉ាវ តាមការព្រមព្រៀងបាន ។ ប៉ុន្តែផ្អែកទៅតាមប្រកា២ នៃប្រកាសលេខ ១២៨ កយ.ប្រក/១១

របស់ក្រសួងយុត្តិធម៌ ការប្រាក់យឺតយ៉ាវនេះ ត្រូវកំណត់មិនឱ្យលើស ២៧% (ម្ភៃប្រាំពីរ ភាគរយ) ក្នុងមួយឆ្នាំវិញ ។ ផ្ទុយទៅវិញ ការកំណត់ប្រាក់ពិន័យដែលមានចែងក្នុងកិច្ចសន្យានេះជាការកំណត់ដែលមិនត្រឹមត្រូវតាមច្បាប់ទេ ពីព្រោះបានកំណត់លើសអត្រាការប្រាក់យឺតយ៉ាវដែលបានកំណត់ក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌ ។ ដូច្នេះគប្បីតុលាការបន្ថយការប្រាក់យឺតយ៉ាវនេះមកត្រឹម២៤%(ម្ភៃបួនភាគរយ)ក្នុងមួយឆ្នាំវិញ ។

**ឃ.ស្ដីពីការទាមទារសំណងជំងឺចិត្ត ការខូចខាត ប្រាក់ពិន័យ**

ឃ.១.ដើមចោទ បានទាមទារឱ្យសហចុងចម្លើយសងប្រាក់ពិន័យមក ដើមចោទចំនួន ១០៨.០០០ (មួយសែនប្រាំបីពាន់)ដុល្លារអាមេរិក ត្រង់ចំណុចទី៤ និងចំណុចទី៥ ទាមទារសំណងនូវការខូចខាត និងសំណងជំងឺចិត្តចំនួន ២០០.០០០(ពីរសែន)ដុល្លារអាមេរិក ។ តុលាការគប្បីមិនសម្រេចពីសំណងជំងឺចិត្ត សំណងនូវការខូចខាត និងសំណងប្រាក់ពិន័យ ទៅឱ្យដើមចោទទេ ដោយហេតុថា សំណងជំងឺចិត្តនេះ នឹងពុំមានទៀតទេ នៅពេលធ្វើកិច្ចសន្យាខ្ចីបរិភោគ ត្រូវបានបង្កើតឡើង ដោយមានភ្ជាប់ជាមួយនឹងការប្រាក់ផង និងមានកំណត់អំពីការប្រាក់ពិន័យផង ព្រោះថាសំណងជំងឺចិត្តនេះ ត្រូវបានទទួលស្គាល់និងបញ្ចូលទៅក្នុងការប្រាក់ និងប្រាក់ពិន័យលើការយឺតយ៉ាវរួចរាល់ហើយ។ដូច្នេះ តុលាការ គប្បីសម្រេចច្រានចោលការទាមទារត្រង់ចំណុចនេះ ។

-អវត្តមានរបស់សហចុងចម្លើយ ពុំមែនជាឧបសគ្គរាំងដល់នីតិវិធីរបស់តុលាការនោះទេ ដោយភាគីចុងចម្លើយបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី១ បានសារភាពទទួលស្គាល់នៅការប្ដឹងទាមទាររបស់ដើមចោទ តែនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនិងកាលបរិច្ឆេទការទាញហេតុផលដោយផ្ទាល់មាត់ ភាគីចុងចម្លើយ ពុំបានចូលថ្លែងការណ៍ទាក់ទងទៅការថ្លែងការណ៍របស់ដើមចោទឡើយ ។

តុលាការ ធ្វើការបញ្ជូនដីកាកោះហៅតាមនីតិវិធីរួចរាល់អស់ហើយនូវលិខិតអញ្ជើញមេធាវី ហើយសហមេធាវី លោក [redacted] និងលោក [redacted] បានទទួលដំណឹងរួចហើយ ដោយជំនួយការមេធាវីឈ្មោះ[redacted]បានចុះហត្ថលេខាទទួលនៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ រួចហើយតែលោក [redacted]អវត្តមានដោយគ្មានមូលហេតុ ចំណែកលោកមេធាវី [redacted] តំណាងឱ្យឈ្មោះ [redacted] Tianxing សុំអវត្តមាននៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ។

ឯសហចុងចម្លើយមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់នោះទេដូច្នេះតុលាការចាត់ទុកថាសហចុងចម្លើយបានសារភាពតាមសេចក្ដីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងទៅនឹងអង្គហេតុនៃបណ្ដឹងរបស់ដើមចោទ ។

**ខ.អំពីការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នត្រង់ចំណុច១**



Scanned with CamScanner

ឃ.១.ការឱ្យអនុវត្តជាបណ្ដោះអាសន្ន ក្នុងចំណុចទី១ ខាងលើ មានលក្ខណៈស្របនឹងមាត្រា ១៩៦នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រោះជាការទាមទារសិទ្ធិលើទ្រព្យសម្បត្តិ គប្បីសម្រេចតាមការទាមទារ ។

**ច.អំពីប្រាក់ប្រដាប់ក្ដី**

ឃ.១. ប្រាក់ប្រដាប់ក្ដី តាមមាត្រា៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បីសម្រេចឱ្យសហចុងចម្លើយជាអ្នកទទួលបន្ទុកលើប្រាក់ប្រដាប់ក្ដី ។

## សេចក្ដីសន្និដ្ឋាន

សហចុងចម្លើយបានទទួលស្គាល់ថា ខ្លួនពិតជាជំពាក់ដើមចំនួន**១.០០០.០០០**(មួយ**លាន**) **ដុល្លារអាមេរិក**ប្រាកដមែន ដូច្នេះដើមចោទ ពិតជាមានអត្ថិភាពនៃសិទ្ធិទាមទារចំពោះសិទ្ធិលើបំណុលនេះ ។ ដោយឡែកពិនិត្យទៅលើកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០៥ ខែវិច្ឆិកាឆ្នាំ ២០១៩ កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២០ និងចុះកិច្ចសន្យាធានា ចុះថ្ងៃទី០៥ ខែ មករា ឆ្នាំ ២០២០ ឃើញថា ពិតជាមានអាត្រាការប្រាក់ និងការប្រាក់ពិន័យដូចការលើកឡើងខាងលើ មែន ប៉ុន្តែ ដោយសារការកំណត់ពីការប្រាក់ពិន័យ មានចំនួនលើសពីអត្រាការប្រាក់ ដែលច្បាប់បានកំណត់ គប្បីបន្ថយការប្រាក់ពិន័យមកត្រឹម**២៤%ក្នុង១ឆ្នាំ**(ម្ភៃបួន**ភាគរយ**)វិញ ។

## សេចក្ដីសម្រេចបញ្ចប់

១.បង្គាប់ឱ្យសហចុងចម្លើយសងប្រាក់ចំនួន **១.០០០.០០០** (មួយ**លាន**) **ដុល្លារអាមេរិក** ទៅឱ្យដើមចោទ ។

២.បង្គាប់ឱ្យសហចុងចម្លើយ សងការប្រាក់ចំនួន**១,៥%ក្នុង១ខែ**(ដប់**ប្រាំភាគរយ**)លើប្រាក់ដើម**១.០០០.០០០**(មួយ**លាន**)**ដុល្លារអាមេរិក** ទៅឱ្យដើមចោទ គិតចាប់ពីថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៩ ។

៣.បង្គាប់ឱ្យសហចុងចម្លើយ សងសំណងនៃការខូចខាតដោយសារការយឺតយ៉ាវ ចំនួន **២៤%ក្នុង១ឆ្នាំ**(ម្ភៃបួន**ភាគរយ**)លើប្រាក់ដើមចំនួន**១.០០០.០០០** (មួយ**លាន**) **ដុល្លារអាមេរិក**ឱ្យទៅដើមចោទ គិតចាប់ពីថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ រហូតដល់ថ្ងៃសងរួច ។

៤.ច្រានចោលការប្ដឹងសុំទាមទារទៅលើចំណុចទី៤ និងទី៥ នៃខ្លឹមសារ ដែលដើមចោទទាមទារ ។

៥.សាលក្រមនេះ អាចអនុវត្តជាបណ្ដោះអាសន្នបានចំពោះចំណុចទី១ នៃសេចក្ដីសម្រេចនេះ ។

៦.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ ។



Scanned with CamScanner

សាលក្រមនេះ ត្រូវបានប្រកាសជាសាធារណៈ នៅថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០២១ ។ ក្នុងករណីដែលប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល១(មួយ)ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រមនេះ ។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

**"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"**

**ថ្ងៃព្រហស្បតិ៍ ១៤រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥**

ខេត្តព្រះសីហនុ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១

**បានឃើញ**

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ខេត្តព្រះសីហនុ,ថ្ងៃទី...ខែ...ឆ្នាំ២០២..១

**ក្រឡាបញ្ជី**

[redacted]